ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# មាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ ៧នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៧នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ស.ជ.ន** អាយុ៣៣ឆ្នាំ និង (២) ពលការិនី **ថ.ជ.ន** អាយុ២២ឆ្នាំ។ អ្នកទាំងពីរមកពីស្រុកសៀមរាប ខេត្តសៀមរាប បានធ្វើដំណើរទៅម៉ាឡេស៊ីដោយខ្លួនឯង និងបំរើការងារជាអ្នកម៉ាស្សា កាលពីឆ្នាំ២០១៦។ ដោយចង់ត្រឡប់មកកម្ពុជាវិញ ពលការិនីទាំង២នាក់ បានស្នើសុំអន្តរាគមន៍ពីស្ថានទូត នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧។ ស្ថានទូតបានជួយសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនី មុនមាតុភូមិនិវត្តន៍របស់អ្នកទាំងពីរ។

ពលការិនី **ស.ជ.ន** និង **ថ.ជ.ន** បានមកដល់ព្រលានយន្តហោះខេត្ត**សៀមរាប** នៅថ្ងៃទី**១០** ខែ**កុម្ភៈ** ឆ្នាំ**២០១៧** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK542 ។

(៣) ពលការិនី **ភ.ស.ទ** អាយុ៤០ឆ្នាំ មកពីស្រុកតំបែរ ខេត្តត្បូងឃ្មុំ ត្រូវបានមេខ្យល់នាំទៅបម្រើការងារតាមផ្ទះនៅម៉ាឡេស៊ី ដោយធ្វើដំណើរតាមរថយន្តកាត់តាមប្រទេសថៃ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦។ ដោយចង់ត្រឡប់ទៅកម្ពុជាវិញ ពលការិនី បានស្នើសុំអន្តរាគមន៍ពីស្ថានទូត នៅថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៧។ ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគដល់ពលការិនី។

(៤) ពលការិនី **ជ.ឡ.អ** អាយុ២៥ឆ្នាំ មកពីស្រុកបារាយណ៍ ខេត្តកំពង់ធំ បានចាញ់បោកមេខ្យល់ទៅម៉ាឡេស៊ីធ្វើការងារតាមផ្ទះ ក្នុងខែកញ្ញា ឆ្នាំ២០១៦។ ដោយពុំអាចទ្រាំនឹងការងារលំបាកបាន នាងបានលួចរត់ចេញពីផ្ទះ Agency (សាមីខ្លួនមិនចាំឈ្មោះ លេខទូរស័ព្ទ និងអាស័យដ្ឋានឡើយ) នៅខែមករា ឆ្នាំ២០១៧ និងបានរស់នៅក្នុងចំណតស្ថានីយរថយន្តក្រុងអស់រយៈពេលមួយខែ ហើយបន្ទាប់មកត្រូវបានតំណាងរាស្ត្រទីក្រុង Puchong នៃរដ្ឋ Selangor ជូនទៅស្ថានទូត នៅថ្ងៃទី០៧ ខែកុម្ភៈ។

ស្ថានទូតបានចេញលិខិតធ្វើដំណើរ សម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី និងឧបត្ថម្ភសំបុត្រយន្តហោះជូន ដើម្បីអោយនាងអាចត្រឡប់មកកម្ពុជាវិញ។

(៥) ពលការិនី **អ.ស.ល** អាយុ២២ឆ្នាំ មកពីស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត កាលពីខែតុលា ឆ្នាំ២០១៦ តាមរយៈមេខ្យល់។ ដោយធ្វើការលំបាក នាងបានទៅស្ថានទូតនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

**(៦)** ពលការិនី **ហ.ស.ម** អាយុ២៥ឆ្នាំ មកពីស្រុកព្រៃវែង ខេត្តព្រៃវែង បានទៅម៉ាឡេស៊ី ធ្វើការជាអ្នកបោសសំអាត កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៦ តាមរយៈមេខ្យល់។ ដោយធ្វើការលំបាក នាងបានស្នើសុំស្ថានទូតនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

និយោជករបស់ពលការិនីទាំង២នាក់ បានផ្ដល់សំបុត្រយន្តហោះ និងចេញថ្លៃបង់ពិន័យឲ្យការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី តាមសំណើរបស់ស្ថានទូត។

**(៧)** ពលការិនី **ស.ម.រ** អាយុ១៩ឆ្នាំ មកពីស្រុកស្ទួល ខេត្តក្រចេះ បានទៅម៉ាឡេស៊ីធ្វើការតាមផ្ទះ កាលពីខែតុលា ឆ្នាំ២០១៦ តាមរយៈមេខ្យល់។ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧ និយោជករបស់ពលការិនី បាននាំនាងមកស្ថានទូត ស្នើសុំជួយរៀបចំឯកសារដើម្បីនាងអាចត្រឡប់មកកម្ពុជាវិញ ដោយសារនាងមានផ្ទៃពោះ ពុំអាចបំពេញការងារបន្តទៀតបាន។ ពលការិនីមានផ្ទៃពោះ តាំងពីមុនទៅម៉ាឡេស៊ី។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ចំណែកនិយោជករបស់ពលការិនីបានទិញសំបុត្រយន្តហោះជូននាង។

ពលការិនីទាំង**៥នាក់** (លេខរៀងទី៣ ដល់ទី៧) នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**១១** ខែ**កុម្ភៈ** ឆ្នាំ**២០១៧** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

ភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ